ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៥៨...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកាត់ដីទំហំ ២២៦ ហិកតា និង ៥៩ អា ចេញពីដីរដ្ឋដែលជាអតីតដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុនអភិវឌ្ឍន៍ដំណាំឧស្សាហកម្ម អ៊ុក ឃុន និងធ្វើអនុបយោគដីទំហំ ២០៨ ហិកតា និង ០៥ អា ជាដីឯកជនរបស់រដ្ឋ ដើម្បីប្រទានកម្មជូនប្រជាពលរដ្ឋចំនួន ១០៤ គ្រួសារ និង រក្សាទុកទំហំ ១៨ ហិកតា និង ៥៤ អា ជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជា កម្មសិទ្ធិលើក្បាលដី ស្ថិតនៅភូមិត្រពាំងខ្លុង ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

កាត់ផ្ទៃដីសរុបទំហំ ២២៦ ហិកតា និង ៥៩ អា ចេញពីដីរដ្ឋដែលជាអតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អភិវឌ្ឍន៍ដំណាំឧស្សាហកម្ម អ៊ុក យុន និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែង ទំហំ ២០៨ ហិកតា និង ០៥ អា និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ ទំហំ ១៨ ហិកតា និង ៥៤ អា ស្ថិតនៅភូមិត្រពាំងខ្លុង ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

ប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១០៤ គ្រួសារ នៅភូមិត្រពាំងខ្លុង ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

**មាត្រា៣ .-**

ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ២៣៧ ក្បាលដី ក្នុងនោះ ក្បាលដីចំនួន ២០៨ ក្បាលដីផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ១០១ គ្រួសារ និងផ្តល់សិទ្ធិកម្មសិទ្ធិសាធារណៈរបស់រដ្ឋចំនួន ១ ក្បាលដី គឺដីសាលារៀន ស្ថិតនៅភូមិត្រពាំងខ្លុង ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

ដោយឡែកក្បាលដីចំនួន ២៨ ក្បាលដី ពុំទាន់អាចចុះបញ្ជីនិងចេញបណ្ណជូនបាន ក្នុងនោះ ២៦ ក្បាលដីជាក្បាលដីគ្មានទិន្នន័យ ប្រគល់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តគ្រប់គ្រងថែរក្សាការពារជាទ្រព្យសម្បត្តិរដ្ឋឱ្យមានប្រសិទ្ធភាព និងក្បាលដីចំនួន ២ ក្បាលដី ជាដីទំនាស់មិនទាន់ដោះស្រាយបាន។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ៨ រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ..........អនក្រ.បក ចុះថ្ងៃទី.......ខែ..........ឆ្នាំ២០២១ ស្តីពីការកាត់ឆ្វៀលដីសរុបទំហំ ២២៦,៥៩ហិកតា ចេញពីផែនដីដីរដ្ឋ ដែលជាអតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ដំណាំឧស្សាហកម្ម អ៊ុក ឃុន និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១០៤គ្រួសារ នូវផ្ទៃដីទំហំ ២០៨,០៥ហិកតា ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ១៨,៥៤ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភូមិត្រពាំងខ្លុង ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

**សញ្ញាសំគាល់**

- ភូមិ
- សាលាឃុំ
- សាលាស្រុក
- ស្ទឹង/អូរមានទឹកជាប្រចាំ
- ស្ទឹង/អូរមានទឹកនៅរដូវវស្សា
- ប្រឡាយ
- ផ្លូវចាក់កៅស៊ូ
- ផ្លូវគ្រួសក្រហម ឬ ក្រាលថ្ម
- ផ្លូវរទេះ ឬ ផ្លូវដើរ
- ព្រំប្រទល់រាជធានី ខេត្ត
- ព្រំប្រទល់ក្រុង ស្រុក ខណ្ឌ
- ព្រំប្រទល់ឃុំ សង្កាត់
- ក្បាលដីដែលបានវាស់វែង
- ព្រំដីស្នើសុំកាត់ចេញពីផែនទីដីសម្បទានសេដ្ឋកិច្ច
- ព្រំប្រទល់ផែនទីដីសម្បទានសេដ្ឋកិច្ច អ៊ុកឃុន

គំរបព្រៃឈើឆ្នាំ២០០២

- ព្រៃស្រោង
- ព្រៃពាក់កណ្តាលស្រោង
- ព្រៃរដៀង១
- ដីព្រៃល្បោះ
- ដីគ្មានព្រៃ

**មាត្រដ្ឋាន 1:12,000**

500 250 0
Meters

Coordinate System : UTM , Zone : 48N
Horizontal Datum : WGS_84 , Grid : 500m

ផែនទីស្រុកភ្នំស្រួច



តារាងចំណុចនិយាមកា

| ID | X | Y |
|---|---|---|
| 1 | 418240 | 1243758 |
| 2 | 418961 | 1243977 |
| 3 | 418982 | 1243934 |
| 4 | 419009 | 1243879 |
| 5 | 419141 | 1243911 |
| 6 | 419269 | 1243941 |
| 7 | 419382 | 1243834 |
| 8 | 419493 | 1243805 |
| 9 | 419584 | 1243829 |
| 10 | 419686 | 1243871 |
| 11 | 419706 | 1243790 |
| 12 | 419710 | 1243772 |
| 13 | 419719 | 1243732 |
| 14 | 419719 | 1243732 |
| 15 | 419733 | 1243631 |
| 16 | 419849 | 1243688 |
| 17 | 419875 | 1243701 |
| 18 | 419942 | 1243734 |
| 19 | 419985 | 1243562 |
| 20 | 420049 | 1243335 |
| 21 | 420113 | 1243216 |
| 22 | 420123 | 1243196 |
| 23 | 420132 | 1243179 |
| 24 | 420270 | 1243181 |
| 25 | 420269 | 1243167 |
| 26 | 420299 | 1243034 |
| 27 | 420335 | 1242894 |
| 28 | 420350 | 1242790 |
| 29 | 420270 | 1242768 |
| 30 | 420115 | 1242645 |
| 31 | 420043 | 1242630 |
| 32 | 420039 | 1242598 |
| 33 | 420111 | 1242567 |
| 34 | 420055 | 1242511 |
| 35 | 419989 | 1242536 |
| 36 | 419954 | 1242493 |
| 37 | 419927 | 1242503 |
| 38 | 419932 | 1242568 |
| 39 | 419852 | 1242593 |
| 40 | 419823 | 1242493 |
| 41 | 419797 | 1242463 |
| 42 | 419802 | 1242415 |
| 43 | 419768 | 1242344 |
| 44 | 419723 | 1242324 |
| 45 | 419689 | 1242357 |
| 46 | 419643 | 1242352 |
| 47 | 419626 | 1242306 |
| 48 | 419507 | 1242366 |
| 49 | 419505 | 1242410 |
| 50 | 419471 | 1242426 |
| 51 | 419440 | 1242366 |
| 52 | 419357 | 1242384 |
| 53 | 419283 | 1242321 |
| 54 | 419238 | 1242366 |
| 55 | 419214 | 1242345 |
| 56 | 419234 | 1242155 |
| 57 | 419156 | 1242045 |
| 58 | 419060 | 1242070 |
| 59 | 419007 | 1242124 |
| 60 | 418990 | 1242209 |
| 61 | 418955 | 1242209 |
| 62 | 418933 | 1242165 |
| 63 | 418926 | 1242178 |
| 64 | 418812 | 1242405 |
| 65 | 418841 | 1242434 |
| 66 | 418827 | 1242539 |
| 67 | 418903 | 1242550 |
| 68 | 418988 | 1242563 |
| 69 | 418952 | 1242646 |
| 70 | 418748 | 1242981 |
| 71 | 418621 | 1243144 |
| 72 | 418527 | 1243249 |
| 73 | 418362 | 1243508 |

